# មជ្ឈមណ្ឌលឯកសារកម្ពុជា

**BMI0114**

## សម្ភាសន៍ជាមួយឈ្មោះ ធាម បិ ភេទប្រុស អាយុ៦០ឆ្នាំ

## មុខងារនៅសម័យខ្មែរក្រហមៈ ប្រធានក្រុមបង្កបង្កើនផល

## មុខងារបច្ចុប្បន្នៈ កសិករ

## ស្រុកកំណើតនៅភូមិកសិណ ឃុំថ្មពួក ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ

## សព្វថ្ងៃរស់នៅភូមិគំរូ ឃុំគំរូ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ

## ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១០

## សម្ភាសន៍ដោយៈ សោម ប៊ុនថន

## ០០:៥០:២៦

## ១៨ទំព័រ

ប៊ុនថន : លោកពូឈ្មោះអីដែរ?

បិ : ខ្ញុំឈ្មោះ ធាម បិ ។

ប៊ុនថន : ពូអាយុប៉ុន្មាន?

បិ : អាយុ៦០គត់ កើតឆ្នាំ១៩៥០ ។

ប៊ុនថន : ពូស្រុកកំណើតនៅណាដែរ?

បិ : ស្រុកកំណើតនៅថ្មពួកនេះឯង នៅបើកំណើតដែលកើតនៅភូមិកសិណ ។

ប៊ុនថន : ភូមិអីវិញ?

បិ : ភូមិកសិណ ឃុំថ្មពួក ហើយដល់មកឆ្នាំ១៩៦៨នេះ ខ្ញុំផ្លាស់ទីលំនៅមកនៅខាងគំរូនេះ ។

ប៊ុនថន : បាទ! ៦៨?

បិ : ៦៨ ហើយគំរូនេះគេចែកឃុំនេះ គឺចែកពីដើមមិញម៉ាទូទាំងនេះគឺឃុំថ្មពួកទាំងអស់ ដល់ក្រោយមកមានថ្នល់មានអីទៅ ។ ដល់ពេលរំដោះនៅរាជរដ្ឋាភិបាលសព្វថ្ងៃមក ចែកឲ្យបាន ២ឃុំ គឺឈ្មោះឃុំនេះឈ្មោះភូមិគំរូ ឃុំគំរូ ។ ដល់ហើយការដែលស្រុកថ្មពួក អឺ!ឃុំថ្មពួកពី ដើមមិញអត់មានផ្លូវថ្នល់ខ្វាត់ខ្វែង អត់មានដីឡូត៍ទេ គឺផ្ទះជាប់គ្នានៅម្តុំផ្សារចាស់យើងនឹង មកនៅម្នាងកើតឯនោះទេ ។ ហើយដល់ពេលចៅហ្វាយស្រុកឈ្មោះ អ៊ូ នាងហេង គាត់ មកឈរនៅថ្មពួកទៅបានធ្វើផ្លូវខ្វាត់ខ្វែងនៅភូមិថ្មពួកចឹងទៅ អាផ្ទះណាត្រូវផ្លូវក៏នាំគ្នាសែន រុញទៅរាស់ដីឡូត៍ចែកឲ្យមកនៅមានថ្នល់មានឡូត៍មានអីខ្វាត់ខ្វែងទៅបានដាក់ឈ្មោះភូមិ នេះជាភូមិគំរូ ។

ប៊ុនថន :  បាទៗ មានប្រវត្តិចឹង?

បិ :  ហ្នឹងមានប្រវត្តិចេះ ។

ប៊ុនថន :  ហើយចុះភូមិកសិណពល់ថ្ងៃនៅក្នុងឃុំអីវិញ?

បិ :  ភូមិកសិណពល់ថ្ងៃ ភូមិរន្ទះ ភូមិកសិណ ភូមិអ្នកតាឯណោះ នៅក្នុងឃុំថ្មពួក ។

ប៊ុនថន :  ឃុំថ្មពួក?

បិ :  ភូមិគុំរូ ចាប់ពីផ្សារថ្មីឯកភាពពីឯនោះមកទាល់នឹងតាឃើងព្រៃវែងនោះអានេះឃុំគុំរូ វាមាន ៦-៧ភូមិដែរ ។

ប៊ុនថន :  ចឹងពូមានបងប្អូនប៉ុន្មាននាក់?

បិ :  ខ្ញុំនៅមានបងប្អូននៅសល់៥នាក់ ១ ២ ៣ ៤ ៥ សល់បងប្អូន៥នាក់ៗ សម័យប៉ុលពត នឹង អឺ!ហើយសម័យក្រោយនេះមកងាប់មួយ ប៉ុលពតចប់ហើយសម័យប៉ាវ៉ា ។

ប៊ុនថន :  គាត់ស្លាប់ដោយសារអី?

បិ :  ស្លាប់ដោយសារចុះឡើងៗទៅជំរំក្បែរភូមិត្រូវមីនម៉ង ។

ប៊ុនថន :  ពូកូនទីប៉ុន្មាន?

បិ :  ខ្ញុំកូនទី៣ ។

ប៊ុនថន :  ចុះឪពុកម្ដាយពូនៅរស់ទេ?

បិ :  ឪពុកម្ដាយខ្ញុំស្លាប់អស់ហើយ ឪពុកម្ដាយក្មេកទេស្លាប់អស់សម័យប៉ុលពតគេវៃចោលអស់

ប៊ុនថន :  ម៉េចបានគាត់?

បិ :  នែក! កាលនោះរត់សម័យលន់ នល់ សម័យពីសង្គម គាត់ធ្វើមន្ត្រីរាជការ ម្ល៉េះហើយគឺមន្ត្រីរាជការ គឺគេគៀរចេញពីឃុំថ្មពួកនេះ ឲ្យចេញទៅនៅបន្ទះស្តៅ ទៅនៅខាងសង្កាត់ឃុំថ្មីៗ ហើយដល់ពេលសម័យគេកាប់សម្លាប់គេហៅនិរតី ពួកនិរតី សម្លាប់ឪពុក ។

ប៊ុនថន :  បាទ! ម្ដាយក្មេក?

បិ :  ម្ដាយក្មេក បងប្អូនទាំងអស់ជុំម៉ែឪ ។

ប៊ុនថន :  ចុះឪពុកម្ដាយលោកពូ ឪពុកម្ដាយបង្កើត?

បិ :  ឪពុកម្ដាយខ្ញុំ ស្លាប់ដោយអស់អាយុធម្មតា ឪពុកខ្ញុំ.... ។

ប៊ុនថន :  ចុះពូបានរៀនសូត្រដល់ថ្នាក់ណា?

បិ :  ខ្ញុំរៀនសូត្រអត់ចប់បឋមទេ ខ្ញុំបានថ្នាក់ទី៧ចាស់ ។

ប៊ុនថន :  ទី៨ចាស់?

បិ :		បាទ! ថ្នាក់ទី៨ចាស់ អត់បានថ្នាក់ទី៧ទេ ។

ប៊ុនថន :	បាទ! ពូរៀនសាលាណា ចុះកាលពី?

បិ :		រៀននៅសាលាបឋមសិក្សាថ្មពួកយើងនេះ ។ មានឃើញសាលា ឃើញ?

ប៊ុនថន :	ឃើញតើពូ ។

បិ :		ជាសាលាបឋមសិក្សានេះគឺ វាបញ្ចប់ថ្នាក់ទី៧ ទី៦បានទៅអនុវិទ្យាល័យ កាលនោះអត់ទាន់ មានទេ អត់មាន ។

ប៊ុនថន :	អនុវិទ្យាល័យទៅណាវិញ?

បិ :		អនុវិទ្យាល័យទើបនឹងបង្កើតក្រោយ ខ្ញុំឈប់រៀនហើយៗបើថាជាប់នោះហើយទៅរៀនស្វាយ អនុវិទ្យាល័យនៅស្វាយ ។ ដល់ក្រោយមកខ្ញុំឈប់បានម៉ាឆ្នាំ២ឆ្នាំ គេបានបង្កើតអនុវិទ្យាល័យនៅថ្មពួកយើងសព្វថ្ងៃនេះ ។

ប៊ុនថន :	ចឹងក្រោយពូឈប់នេះនឹងពូទៅធ្វើអីវិញ?

បិ :		អឺ! ដល់ខ្ញុំឈប់វិញ ខ្ញុំទៅបួសបានជាងម៉ាឆ្នាំៗ ខ្ញុំឈប់រៀនៗសម័យប៉ុលពតចូលបណ្តោយ ។

ប៊ុនថន :	បាទ! បួសនៅវត្តណា?

បិ :		បួសនៅវត្តថ្មពួក ។ ហើយដល់សឹកមកក៏សង្គ្រាមចូលដល់ក៏មានស្អី មានតែការពារក្រវ៉ាត់ភូមិអត់បានធ្វើទាហាននឹងគេទេ គ្រាន់ការពារក្រវ៉ាត់ភូមិ ព្រោះថាខ្មែរក្រហម វាជិតចូលដល់ថ្មពួកហើយ ស្តៅ ត្រគៀក នៅខាងកើតភូមិទ្រាស ឃុំគោកកបិននោះ ។ ហើយដល់មើលទូរទស្សន៍គេវៃចូលបានទូទាំងប្រទេសចឹងហ៊ា ។

ប៊ុនថន :	បាទៗ ប៉ុនអឺ!

បិ :		ជិតដល់ដាច់ឆ្នាំនែក១៩០០!

ប៊ុនថន :	១៩៧៥?

បិ :		១៩៧៥ ។

ប៊ុនថន :	កាលនោះពូសឹកនៅ?

បិ :		ខ្ញុំសឹកហើយ ។

ប៊ុនថន :	សឹកបានប៉ុន្មាន?

បិ :		សឹកបានម៉ាឆ្នាំ បានគ្រួសារ ។

ប៊ុនថន :	គ្រួសារលោកពូនៅនេះដែរ?

បិ ៖ នៅនេះដែរ ។

ប៊ុនថន ៖ ភូមិឃុំនេះដែរ?

បិ ៖ នែក!អត់មាន បើម៉ែឪអត់មាននៅនេះទេ ហើយដែលគាត់ផ្លាស់មកនៅនេះយូរហើយ ផ្លាស់ស្រុកញឹក ។ នៅថ្ងៃដែលខ្ញុំបាននឹង នែក!ប៉ុលពតគេចូល បានគ្រួសារនឹង ។ ដល់ឆ្នាំ ៧៥ដែលប៉ុលពតមក គឺខ្ញុំបានគ្រួសារនេះ ហើយខ្ញុំថារៀបការ គេអត់រៀបការទេ ហើយ អត់មានអីគេឲ្យសែនធម្មតាទៅសុំច្បាប់គេ ឲ្យដាក់ខាន់ស្លា១៦រៀល ថានឹងការខែពិសារ នេះ ក៏ចូលខែចែត្រ។ យើងត្រូវការខែវស្សា ។ ម្ល៉ះហើយដល់នេះទៅអត់មានអីទេ ថា យើងឲ្យមហាពរធម្មតាទៅ គ្រាន់តែយើងអត់មានខាន់ស្លារាប់ពាន់រាប់ម៉ឺនទេ គេឲ្យដាក់១៦ រៀល ប្រាក់រៀលយើង ។

ប៊ុនថន ៖ បាទ! ស្មើប៉ុន្មានដីកាលនឹង?

បិ ៖ បានដីអី រៀលអីវាច្រើនប៉ុន្មានវា ម៉ាតិចម៉ាតួចនឹងឲ្យតែមានម៉ាដីស្មើហ៊ុនអីទេ ។

ប៊ុនថន ៖ ប៉ុនពូការ ពូសែនតាមកំណត់ដែលពូគ្រោងទុកពីមុនមក?

បិ ៖ បាទ! មានតាមទំនៀមទម្លាប់ដែរ មានមហា ប៉ុន្តែគេអត់រកមេគ្រូបានគេលាក់ទុកអស់ ហើយ គេមិនឲ្យប្រើទេ ។

ប៊ុនថន ៖ ក្រោយពីការហើយពូនៅជុំគ្នាទាំងអស់ ឬមួយគេផ្លាស់ប្តូរយ៉ាងម៉េចដែរ ពូនៅភូមិឃុំនឹង?

បិ ៖ ការហើយនៅនឹងកន្លែងនិយាយនឹង អត់ផ្លាស់ប្តូរទៅណាទេ ។ ដល់ការរួចហើយក្នុងម៉ាឆ្នាំ ៧៩នឹង នែក!គេអត់ឲ្យទៅណាទេ ។ ដល់គេបង្កើតសហករណ៍បានគេផ្លាស់ ហើយគេចែក សាខាទៅបានខ្ញុំគេឲ្យទៅនៅភូមិតាយឹង ឃុំគុំរូដែលប៊ុននៅភូមិតាយឹងឯលិចនឹង ប្រហែល ជា៥គីឡូពីថ្មពួកទៅ ។ ទៅនៅភូមិតាយឹង ដល់ពេលចប់បានចូលមកដី ។

ប៊ុនថន ៖ ចប់?

បិ ៖ ចប់ជំនាន់ប៉ុលពត ដែលវាវៀតណាមរំដោះ ។

ប៊ុនថន ៖ ហើយទៅជាមួយគ្រួសារពូ?

បិ ៖ ទៅទាំងអស់ ភូមិទាំងគ្រួសារ ។

ប៊ុនថន ៖ ឪពុកម្តាយបងប្អូន?

បិ ៖ ពុក អត់មានទេ មានតែប្តីប្រពន្ធ កាលនោះបានកូនមួយរត់មកនេះ ខ្ញុំបានពីដើមឆ្នាំចុងឆ្នាំ ខ្ញុំកើតកូនប្រុសមួយអាបងគេទៅរៀនសព្វថ្ងៃនឹង ។

ប៊ុនថន ៖	ពូទៅនៅភូមិគាយើងធ្វើអី?

បិ ៖	នែក! ទៅនោះមិនបានធ្វើអីជាធំដុំទេ គ្រាន់តែធ្វើជាមេក្រុម ដើម្បីបង្កបង្កើនផលប៉ុននោះឯង ។

ប៊ុនថន ៖	បាទ! ប្រធានក្រុម?

បិ ៖	បាទ! ប្រធានក្រុម ដឹកនាំបង្កបង្កើនផលប៉ុននោះឯង ធ្វើស្រែ ។

ប៊ុនថន ៖	ចុះមានធ្វើនៅតែនៅក្នុងភូមិ ពូក៏មានចេញទៅភូមិផ្សេងៗ?

បិ ៖	អត់ទេ ធ្វើតែនៅក្នុងភូមិ គ្រាន់ថាការដ្ឋានចុះទៅតាមស្រែជិតៗ ។

ប៊ុនថន ៖	ចុះទៅនោះមានប្រជាជនថ្មីៗទៅនៅ ប្រជាជនជម្លៀស?

បិ ៖	មានៗខ្លះ ប្រជាជនថ្មីគឺប្រជាជនថ្មី គឺប្រជាជនដែលជម្លៀសចេញពីភ្នំពេញមកគេដឹកតាមផ្លូវក្នុងស្រុកមកចុះត្រពាំងថ្មមក ។ អ្នកថ្មពួកយកប្រជាពលរដ្ឋអ្នកភ្នំពេញធ្វើការជាមួយខ្ញុំ ២-៣គ្រួសារ ដែលមានជិតអ្នកភ្នំពេញ មានអ្នកធ្វើការ សាស្ត្រាចារ្យ គ្រូបង្រៀននៅជាមួយខ្ញុំដែរ ។

ប៊ុនថន ៖	បាទ! នៅជាមួយពូដែរ?

បិ ៖	អ្នកមកពីភ្នំពេញ សួរបងប្តីទៅណាទៅណែ"ប្តីខ្ញុំក្រសួងការបរទេស ហើយដល់គេបញ្ចូលមកទៅ ខ្ញុំបែកគ្នា" ។

ប៊ុនថន ៖	គេមានប្រាប់ឈ្មោះថាពូ ឈ្មោះអីទេ?

បិ ៖	ឈ្មោះអី មិនប្រាប់ទេ ខ្ញុំសួរដឹងដែរ បើគាត់ស្រីនៅជាមួយខ្ញុំឈ្មោះ វ៉ាៗ ។

ប៊ុនថន ៖	ឈ្មោះវ៉ា?

បិ ៖	ប្តីនោះឈ្មោះអីទេ ខ្ញុំមិនបានសួរទេ ។

ប៊ុនថន ៖	គ្រាន់តែប្រាប់?

បិ ៖	ប្រាប់ ។

ប៊ុនថន ៖	ចុះអ្នកផ្សេងៗទៀត គាត់ធ្វើអី?

បិ ៖	អ្នកផ្សេងៗអត់មានធ្វើអីទេ ប៉ុននៅជុំបងប្អូន ប៉ុនគ្រាន់ថាការងារដែលត្រូវបិទទំនប់ ត្រូវទៅធ្វើទៅអីគេប្រាប់នាំទៅៗ ធ្វើធម្មតា ។

ប៊ុនថន ៖	៣គ្រួសារ?

បិ ៖ ៣គ្រួសារ ចិនម៉ាគ្រួសារ បងប្អូននោះវាមាន២គ្រួសារ បងប្អូននោះបងថ្លៃប្អូនថ្លៃមានប្រពន្ធប្តី២នាក់ៗ ប៉ុនបងនោះគាត់បែកគ្នាប្តីនៅនោះ មីប្អូននោះមានប្តីមកជាប់ជាមួយហើយនឹងមានចិនម៉ាគ្រួសារទៀត ។

ប៊ុនថន ៖ បាទ! អ្នកសុទ្ធតែអ្នកមកពីភ្នំពេញ?

បិ ៖ អ្នកមកពីភ្នំពេញ ។

ប៊ុនថន ៖ បាទ! ៣គ្រួសារ មានកូនតូចៗ?

បិ ៖ មានៗតូចៗ ដល់ពេលស្រុកដាក់ពួកប៉ុរ៉ាគេនៅនេះ គេរត់ទៅថៃៗ ។

ប៊ុនថន ៖ ចុះក្នុងភូមិនេះដូចថាមានផ្លាស់ប្តូរពូ ដូចថាពេលខ្មែរក្រហមចូលមក ដូចថាអ្នកដឹកនាំចាស់ៗដឹកនាំសម័យលន់ នល់អីមានផ្លាស់ចេញទេ?

បិ ៖ អឺ! កាលនឹង កាលដែលនេះចូលមកឆ្នាំ៧៥ ៧៦ ខ្ញុំប្រាប់ហើយអ្នកដែលចាស់ៗដែលធ្វើ ទាហាន ធ្វើគ្រូអីក៏ដោយឲ្យតែជាប់និន្នាការ លើកឡើងថាជាប់និន្នាការនយោបាយគេជម្លៀសចេញអស់អត់មានឲ្យនៅទេទាំងអស់ ទាំងគ្រូ ទាំងប៉ូលីស ឪពុកក្មេកខ្ញុំប៉ូលីសតើទាំងអស់ឲ្យចេញផុតពីទឹកដីថ្មពួក ឲ្យទៅរស់នៅខាងឃុំគោកកបិននោះ ។

ប៊ុនថន ៖ គោកកបិន?

បិ ៖ បាទ!

ប៊ុនថន ៖ ទៅនៅនឹងមានយកទៅណាបន្តទៀតទេ?

បិ ៖ មានទៅណា ដល់ចុងក្រោយវៃចោលអស់ ។

ប៊ុនថន ៖ វៃចោលនៅនឹង ឬនៅណា?

បិ ៖ វៃចោលនៅផ្ទះគេលិច ដឹងៗ តាំងពីសង្គ្រាមហើយរស់ៗពួកចិនខ្លះ បើពួកបម្រើនយោបាយគេគឺវាប់ទាំងអស់ ។

ប៊ុនថន ៖ ហើយចុះអ្នកណាអ្នកគ្រប់គ្រង?

បិ ៖ គ្រប់គ្រងគឺ បើថាគ្រប់គ្រងដូចចៅសង្កាត់រាយការតែគ្នាគេទៅ ។

ប៊ុនថន ៖ ចៅសង្កាត់ឈ្មោះអី?

បិ ៖ អាប្រជាជនចាស់ដែលគេមកពីរំដោះមុននោះ ពីខាងកើតដែលគេមកកាន់កាប់យើងខបមាខ្ញុំមកមុនចេះទៅ ហើយដល់គេមកក្រោយទៅ គេដកខ្ញុំចេញ គេមកផ្លាស់តែគ្នាគេ អត់មានផ្លាស់យើងទេៗ យើងគ្រាន់ថាជាអ្នកប្រធានក្រុម ជាឈ្លបភូមិ ជាឈ្លបឃុំ ហើយគេប្រធានៗសុទ្ធតែគេ ។

ប៊ុនថន ៖ ចៅសង្កាត់?

ប៉ិ ៖ ចៅសង្កាត់ក៏គេ ។

ប៊ុនថន ៖ បាទ! ចឹងដំបូងចៅសង្កាត់ថ្មពួកនឹងឈ្មោះអី?

ប៉ិ ៖ អឺ!អារឿងថាចៅសង្កាត់ថ្មពួក គេមកពីនោះឈ្មោះ សាំ ។

ប៊ុនថន ៖ សាំ?

ប៉ិ ៖ នោះហើយ បើថាដល់ចែកសហករណ៍ទៅ ប្រធានសហករណ៍...ឈ្មោះ តាឆាន់ ។

ប៊ុនថន ៖ តាឆាន់?

ប៉ិ ៖ នោះហើយ ។

ប៊ុនថន ៖ ដំបូងគេ?

ប៉ិ ៖ ដំបូងគេបំផុត ។

ប៊ុនថន ៖ ចឹងក្រោយមកមានប្តូរទេ?

ប៉ិ ៖ ប្តូរ ខាងនិរតីមកស្រី ឈ្មោះនេះ មិនទាន់នេះទេផ្លាស់តាឆាន់ទៅ បានប្រធានសហករណ៍ គេកាន់នៅនេះគឺឈ្មោះនែក! ឈ្មោះប៉េនៗ ប៊ុនប្អូនឯងក្មេង ។ តាំងពីផុតមកនិរតីមកគេកាន់ គឺមេភូមិស្រីឈ្មោះថន ។

ប៊ុនថន ៖ ថនដែរ?

ប៉ិ ៖ ហ្នឹងហើយឈ្មោះថន មេភូមិខាងនិរតីគេចូលមក គេកាន់ក្រោយនេះ ។

ប៊ុនថន ៖ ភូមិអីគេ?

ប៉ិ ៖ ភូមិគំរូនេះ សហករណ៍គំរូ ។

ប៊ុនថន ៖ បាទ! សហករណ៍គំរូ?

ប៉ិ ៖ គេហៅសហករណ៍ថ្មពួក សហករណ៍គំរូ ។

ប៊ុនថន ៖ បាទ! ភូមិពូនៅក្នុងសហករណ៍នឹងដែរ?

ប៉ិ ៖ នៅក្នុងសហករណ៍ ហើយនៅកន្លែងសហករណ៍គេធ្វើរោងធំសម្រាប់ដាក់ទំនិញ ហើយការិយាល័យគេធ្វើការ ។ ហើយយើងប្រជាពលរដ្ឋនេះ ក៏គ្រាន់ថាយ៉ាងណាក៏បើថាកូនឈ្លបគេ ស្អីមេគេ អីៗលើគេទាំងអស់ គេមិនឲ្យយើងគ្រប់គ្រងឲ្យយើងមានប្រធានទេ ។ បើថាគេ មេមួយ បើថាគេរើសជំនាញនេះយើងវង ។

ប៊ុនថន ៖ ម៉ាសហករណ៍គំរូមានប៉ុន្មាន ក្រុម?

បិ : សហករណ៍គំរូមាន៣ក្រុម ក្រុម... ក្រុមឈ្មោះនែក! បងហឿនម៉ាក្រុម ឈ្មោះ តាហាន់ម៉ាក្រុម ។ ក្រុមយើងនៅនេះម៉ាសហករណ៍ចែកជាសាខាមាន៣ក្រុមធំ ។ ក្រុមធំនៅនេះមួយ នៅតាយើងនោះ២ ខ្ញុំមួយបងខាន់មួយ ។

ប៊ុនថន : ទាំងអស់ប៉ុន្មាននាក់ម៉ាសហករណ៍?

បិ : ម៉ាសហករណ៍មនុស្សរាប់ពាន់ រាប់រយ ក្នុងម៉ាកងៗក្រុមធំៗវាមានមនុស្សជាប់រាប់រយ ។

ប៊ុនថន : គ្រាន់ម៉ាកងពូប៉ុន្មាននាក់?

បិ : ម៉ាកងបើថាមនុស្សម៉ាគ្រួសារវាមិនច្រើនប៉ុន្មានទេ ធ្វើការថា៣០គ្រួសារ ៤០គ្រួសារទៅតាមតិចតាមច្រើន ទៅតាមដែលដាក់ឲ្យខ្ញុំក៏រៀង តិចជាងគេយ៉ាងតិច៥០គ្រួសារ ៣០គ្រួសារ ហើយបើមនុស្សវារាយទៅ យើងមានទៅរកណា៥០គ្រួសារ ៤០គ្រួសារ ខ្លះក៏៦០ទៅ បើនៅនោះច្រើន ខ្ញុំមិនបានដឹងទេ នៅនេះច្រើនជាងគេទៅនោះ៣ត្រង់ ។ នៅនេះច្រើន រាប់រយគ្រួសារ វាមិនទៀង ។

ប៊ុនថន : ចុះដូចគណៈស្រុកអី គាត់ដំបូងពីណាគេ?

បិ : គណៈស្រុកគេដំបូងទី១ ចាំមើលណាគណៈស្រុកប្រធានគឺលោកហួត លោកឆាត នែក!ណា មួយទៀតទេ ខ្ញុំភ្លេចហើយចាំមិនបានទេ ។

ប៊ុនថន : រិទ្ធិឈ្មោះរិទ្ធិ?

បិ : នែក! រិទ្ធិនោះគេអ្នកខាងស្រុកក្រោយ ស្រុកទី២ រិទ្ធិនោះនៅគេអូគេបញ្ជូលទៅស្រុកក្រោយ ពីដើមមិញលោកឆាត លោកហួតជាចៅហ្វាយស្រុក ។ ហើយដល់ពួកនោះដែលគេចោទក្បត់ គេដកយកទៅសម្លាប់ចោលទៅ ឲ្យលោករិទ្ធិធ្វើចៅហ្វាយស្រុកម្តង ។ ធ្វើចៅហ្វាយស្រុកទៅដកលោករិទ្ធិយកទៅវៃចោលអស់ទៅ ។ ហើយដល់ខាងនិរតីមក យួនរំដោះបានគេរត់ចេញ ។

ប៊ុនថន : ចុះដូរមិត្តរិទ្ធិនឹង ពីណាមក?

បិ : នែក! លោករិទ្ធិនោះមក ចៅហ្វាយស្រុកនោះមក នែក!ពួកនិរតីគេបានបាត់ហើយ និរតីគេចូលមកបាត់ហើយ ។

ប៊ុនថន : និរតីពីមកណា?

បិ : ដឹងអ្នកណា គេថាមកពីនិរតី គេហៅពួកនិរតីនឹង មិនដឹងនិរតីឃើញមកពីណា ។

ប៊ុនថន : បាទ! ដូរមក?

បិ : ដូរមកកាន់បន្តគ្នា ។

ប៊ុនថន : ចុះនេះនៅក្នុងតំបន់៥?

បិ : តំបន់៥ ។

ប៊ុនថន : តំបន់៥ ពីណាគណៈតំបន់?

បិ : គណៈតំបន់អត់ស្គាល់គេទេ កន្លែងតំបន់នៅណា ឈ្មោះដល់តំបន់អត់ស្គាល់ទេ ស្គាល់ត្រឹមស្រុក ។

ប៊ុនថន : ហើយនារីថាប្រធានសហករណ៍ពូនឹងឈ្មោះ?

បិ : ប្រធានសហករណ៍គំរូឈ្មោះ នាងថូន ។

ប៊ុនថន : គាត់មកពីនិរតី?

បិ : គាត់មកពីនិរតី ។

ប៊ុនថន : គាត់មានដូរចេញក្រោយមក?

បិ : ទេ! ដល់វៀតណាមបាញ់រំដោះវៃតគ្នាទៅវារត់ ។

ប៊ុនថន : ប៉ុនគាត់នៅរហូតដល់វៀតណាមចូលមក?

បិ : ហ្នឹងហើយនៅដល់វៀតណាមចូលមក បាននាំទាល់តែចាញ់វៀតណាមទៅក៏រត់ទៅព្រំដែនថៃ រត់ទៅផ្លូវនេះទៅក៏បាត់ជ្រាបទៅ ។ ហើយដល់ពេលវៀតណាមដកទៅ ក៏ចូលមកវិញ វៀតណាមមកថ្មពួក ចូលរំដោះបានហើយឡប់ទៅវិញ ចឹងបានវាពិបាក ។

ប៊ុនថន : គ្រួសារអ្នកជម្លៀសមកពីភ្នំពេញតែ៣គ្រួសារ មានជម្លៀសមកក្រោយៗចូលកងពូទៀតទេ?

បិ : អត់ រត់ទៅនោះខ្ញុំមានតែ៣គ្រួសារ មានចិនម៉ាគ្រួសារ មានសាស្ត្រាចារ្យស្រីខាងគ្រូបង្រៀនម៉ាគ្រួសារ ២គ្រួសារបងប្អូនគាត់ចឹង ។

ប៊ុនថន : ចុះមកធ្វើស្រែចេះធ្វើស្រែទេ ដូចមកពីភ្នំពេញអីចឹង?

បិ : ទេ! អារឿងនោះចេះក៏ដូចថាមិនចេះ ទៅហើយ ខ្លះទៅការងារប្រុសទៅបើថាស្រីៗទៅពិបាកធ្វើការតាមគេ...ប្រុសៗ យើងមិនមានគោក្របី ចបកាប់គល់កាប់អីនឹងស្រែប្រុសពួកស្រីៗ ពួកខាងកូនក្មេងនារីទៅខាងចល័តនារីទៅ យុវជនទៅខាងយុវជនទៅ កុមារវ័យជំទង់ប៉ុនកូនមិញទៅតាមកងវាទៅវា ទៅទាំងអស់អត់មានអ្នកណានៅនឹងម្ដាយ ។ នៅនឹងម្ដាយជាប់ដោះទេ ។ តែនេះហើយបំបែកហើយ យុវជនក៏មានប្រធានយុវជន នារីក៏មានប្រធានយុវនារីទៅ ហើយកុមារក៏មានលោកគ្រូនាំធ្វើការទៅ បង្រៀនតិចតួចទៅច្រើនមិនបានបង្រៀននាំទៅធ្វើដីទៅ ទាំងប្រុសទាំងស្រីមានប្រធានទៅ ។ ហើយម៉ែឪដាំដីតាមការ

ដ្ឋាននៅតែប៉ុននឹងមូលដ្ឋានតាមក្នុងភូមិវាអត់មានអ្នកណាទៅទេចុះទៅបាត់ អត់មាននៅទេ ផ្ទះស្ងាត់ជ្រាប ។

ប៉ុនថន : ប៉ុនដូចថាមកដីបូងអី?

បិ : មកដីបូងគេចូលមកដល់គេឲ្យចែកក្រុមធ្វើស្រែ ១៥គ្រួសារ ១០គ្រួសារអី ចែកធ្វើស្រែ ក្រុម ចែកដី ពុះដីចែកគ្នាធ្វើរួមគ្នាទាំងអស់ ។

ប៉ុនថន : ចុះហូបចុកអី?

បិ : ហូបចុកអី នែក!

ប៉ុនថន : យើងមកសហករណ៍?

បិ : ហូបចុកគេធ្វើផ្ទះបាយ ក្នុងម៉ាក្រុមនឹងគេធ្វើផ្ទះបាយមួយសម្រាប់ហូបរួម ដីផ្ទះបាយនេះ នេះដីផ្ទះខ្ញុំ ដីខ្ញុំនេះម៉ាកន្លែង នេះម៉ាក្រុមៗម៉ាជួរម៉ាក្រុមចេះធ្វើផ្ទះបាយមួយសម្រាប់វៃ ដួងមើលទៅ ឧបមាហូបមុនទៅ ហើយយើងរួច ទើបឲ្យចាស់ៗក្រោយទៅទាំងអស់គ្នា ដំណាលចាស់ៗដូចថាមិនបានអីមុន ។ ទៅនោះគេធ្វើបាបហូបរួម ។

ប៉ុនថន : ចុះហូបអីបានប៉ុន្មានពេលដែរ?

បិ : ហូបបានតែ២ពេល ដល់ចុងក្រោយឆ្នាំអាទី២ ទី៣នេះ ឯងមិនឲ្យឯងស៊ីឆ្អែតទេ ឲ្យហូបតែ បបរ ។

ប៉ុនថន : បាទ! ចុះពូធ្វើម៉េច?

បិ : ផ្លាស់ពីពាក់កណ្ដាលឆ្នាំចូលដីបូងបានបាយហូប ឆ្នាំទី២បបររឹងៗ ឆ្នាំទី៣បបររាវៗសុទ្ធ ។ គេឲ្យហូបបបរៗ អ្នកហូប អ្នកណាលួច តែលួចគេគិចគេវៃចោល ។ តែឃ្លានរបស់រួច របស់ខ្លួនឯងចេះ ដាំបានមុនគេរំដោះទៅគេមិនឲ្យស៊ី ។

ប៉ុនថន : ចុះមានគេអ្នកនេះ អ្នកដូចថាលួចហូបឯកជនអី?

បិ : លួចៗហូបឯកជនកុំឲ្យគេឃើញ តែលួចស្អី ។

ប៉ុនថន : កងពូមានទេ?

បិ : មានដូចតែគ្នា គ្រាន់តែរបស់ដូចថាគេមានក្រុមគេ គេចាប់បានគេយកទៅវៃចោលចំពោះ យើង.........ទៅលួចបានហូបទៅ តែលួចពួកឈ្លបគេពិសេសគេដើរការពារ ។

ប៉ុនថន : ចុះមានដូចថា មានពូប្រាប់ថាអត់ធ្វើតាម?

បិ : ខ្លះធ្វើតាម ខ្លះអត់ធ្វើ ព្រោះឃ្លាន សុទ្ធអ្នកឃ្លាន ។ ប៉ុនឃ្លានវាចចេះនេះហើយ ខ្លះមាន អ្នកខ្លះទៅចេះទៅលួចគេឆ្ងាយៗបាត់រូបមានគ្រប់ក្រុម ។

ប៊ុនថន : មានបាត់ដែរ?

បិ : មានបាត់រូបខ្លះដែលចូលខបមាថាទៅឆ្ងាយ ទៅធ្វើការតាមសហករណ៍គេផ្សេងៗដូចខាងឃុំគោករមៀតបណ្ដោយគេចាប់បាន អត់បានបញ្ជូនទេ សម័យនោះគេវ៉ៃចោលដែរ វេទនាណាស់ ។

ប៊ុនថន : ចុះដូចកងពូអីធ្វើស្រែគេមានកំណត់អីឲ្យធ្វើ?

បិ : មានតើ មានកំណត់ឲ្យធ្វើ អ្នកសន្ទូង អ្នកភ្ជួរ ក្នុងម៉ានង្គ័ល៨-៣ក្នុងម៉ាហិចតាភ្ជួរឲ្យរួច អ្នកស្ទូងប្រហែល១០នាក់ស្ទូងឲ្យរួចក្នុងម៉ាហិចតា ។ អ្នកភ្ជួរក៏ដោយ នង្គ័ល៨នេះធ្វើម៉េច ម៉ាហិចតាធ្វើឲ្យរួច នង្គ័ល៩បេះរៀងធូរ ។

ប៊ុនថន : ប៊ុនបើសិនជា ចង់និយាយថាធ្វើអត់រួចពូចាត់ចែងម៉េច?

បិ : ប៊ុនបើដឹងថាផែនការបើមិនដឹងផែនការបានរួច អ្នកភ្ជួរបាននេះទៅក៏រាស់បណ្ដើរ អ្នកស្ទូងបណ្ដើរទៅ អ្នកដាក់សំណាបដាក់ឲ្យគេទៅ អ្នកស្ទូងចាំស្ទូង អ្នកភ្ជួរគិតរឿងភ្ជួររាស់ឲ្យគេ ។ បើអារឿងថាភ្ជួររាស់សម្លាប់អត់មានទេ បើគេៗថ្នាក់លើបើថាធ្វើអី មិនគ្រប់ផែនការ ហើយមិនរួចផែនការ គេបន្ទោសថាខ្ញុំខ្លាំងជាងគេថាខ្ញុំដឹកនាំខ្សោយ ។ ថាយើងមេអ្នកដឹកនាំខ្សោយអត់ខ្លាំង មិនដឹងខ្លាំងយ៉ាងណា ។

ប៊ុនថន : ចឹងពូដែលគេដូចថាដែលគេធ្វើអត់ហើយ គេហៅមកប្រជុំទេ?

បិ : ហៅៗ សួរថាមើលទៅយើងនៅឆ្ងាយ ត្រឡប់ទៅថ្នូពួកធ្វើរងគេ.......នោះឯងគេហៅមិត្តនេះ សុទ្ធតែគេធ្វើការមិនខ្លាំងមិនពូកែ ។ ខ្ញុំធម្មតាតែប៊ុននឹង ដែលនេះទៅ គួរពិចារណាមើល....បើវាលោកឯងនេះឯងថ្ងៃមុខថ្ងៃក្រោយត្រូវពង្រឹងត្រូវខំធ្វើយ៉ាងម៉េចកុំឲ្យចលនាយឺតយ៉ាវ ។ ខ្ញុំប្រឹងបើថាយ៉ាងណាថ្ងៃក្រោយ បងប្អូនឯងខំធ្វើយ៉ាងណាក៏បានប៉ុននេះៗម៉ោង៦ម៉ោង គ្រាន់បើបន្តិច នៅសល់តិចអ្នកណាធ្វើរួចទៅមិនមានបញ្ហាប៉ុន្មានទេអាចអនុគ្រោះឲ្យដែរ ។ បើថារឿងចុះៗមិនអីទេ គ្នាខំមួយភ្លែតៗឲ្យធ្វើចឹងគេពិនិត្យដែរ គេដើរមើលដែរ មានគេធំជាងយើងទៀត ត្រួតពីលើយើង គេពិនិត្យលើយើងទៀត ទទួលឃើញយើងធ្វើមិនឈប់ មិនឈរ បានរួច បើថាមិនរួចទាំងអស់គ្នា អាខ្លះក៏រួច ពិនិត្យបេះឯង ។

ប៊ុនថន : បាទ! ខាងណាហៅមកណែនាំ ដូចថាហៅមកណែនាំ?

បិ : ប្រធានសហករណ៍គេ គេអ្នកនៅកាន់ក្ដាប់សាខាគេមួយៗដែរ ។ នៅបញ្ចុះនៅប្រចាំការណ៍ជាប់នឹងជាមួយកងយោធា៣ ។

ប៊ុនថន : ចុះពូដូចថាណែនាំចឹង ពូមានដូចថាខិតខំធ្វើអី ក៏ពូធ្វើតែធម្មតា?

បិ : ហ៎! ណែនាំរឿងខិតខំ ធ្វើធម្មតា ធ្វើយ៉ាងម៉េច... ឲ្យពន្លឿនទៅ គេក៏រូចយើងយ៉ាងណា គេគោរពយ៉ាងណា យើងគោរពយ៉ាងណា គេក៏មានដៃប៉ុន្មានយើងក៏មានជើងប៉ុន្មាន ជើង ២ដៃ២ដូចតែគ្នា និយាយតែអ្នករូចយើងកែប្រែដែរ ។

ប៊ុនថន : ប៉ុន្តែមានក្រុមផ្សេង ខ្សោយជាងក្រុមពូ?

បិ : វាមានអ្នកខ្សោយអ្នកខ្លាំង ។

ប៊ុនថន : ដូចខ្សោយអីគេចាត់វិធានការណ៍យ៉ាងម៉េច ដោះដូរ?

បិ : មានអី គេដោះដូរមេ ដល់នេះទៅឧបមាថាយើងខ្សោយ យើងទៅនៅឲ្យគេមេកងគេដែលខ្លាំងគេមកនៅកងយើង យើងទៅនៅកងគេ ។

ប៊ុនថន : ដូរចឹង មិនមែនដកទៅណាទេ?

បិ : អត់ដកទៅណាទេ គ្រាន់តែដូរៗម្តុំទេ ឲ្យមេគេទៅនៅកងយើងក្រុមយើងមេយើងទៅនៅកងគេ ឲ្យគេពង្រឹងទៅ អត់មានធ្វើអីទេ ។ គ្រាន់តែដូរមេ-ខយកមកដាក់មេ-កៗទៅដាក់ ។

ប៊ុនថន : ចុះពូក្រុមផ្សេងៗក្រៅពីក្រុមពូនឹង មានចូលមកអ្នកជម្លៀសដូចក្រុមជម្លៀសមកពីភ្នំពេញ ឬមកពីខេត្តផ្សេងៗ ចូលមកនៅដែរ?

បិ : មានតើ ។

ប៊ុនថន : តើអ្នកទាំងនឹង?

បិ : មានៗតិចៗណាស់ មានពួកច្រើន មានពួកចិននឹងឯង ពួកចិននៅភ្នំពេញ ។

ប៊ុនថន : ....? (គាត់ក្អក)

បិ : អត់មានទេ មានតែពួកចិត្ត ។

ប៊ុនថន : ប៉ុនអ្នកដែលមកនឹងមានជម្លៀសទៅណាផ្សេងទៀតទេ ឬដកទៅណាទេ?

បិ : អត់ទេៗ ។

ប៊ុនថន : នៅនឹង?

បិ : នៅដល់វៀតណាមចូលមកស្រុក ។

ប៊ុនថន : ហើយអ្នកជម្លៀស៣គ្រួសារនៅជាមួយពូនឹង គាត់នៅទេ ពេល?

បិ : អត់ទេ អត់នៅទេ រត់ទៅថៃ អឺ!គេទៅភ្នំពេញវិញបាត់ មានដែលគេនៅ ។

ប៊ុនថន : រត់ទៅថៃពេលវៀតណាមចូល?

បិ ៖ កាលពីវៀតណាមរំដោះហើយ ពួកប៉ុំភ៉ានៅតាមដុបតាមព្រៃយកទៅ ។

ប៊ុនថន ៖ ចុះពូនៅកងនឹង ពូមានដែលសន្តិបាលឈ្មោះ ខន ពូដែលស្គាល់?

បិ ៖ ទេ! អត់ ។

ប៊ុនថន ៖ ឈ្មោះ ខន ឈ្មោះ សក្តិអីដែលស្គាល់ទេ?

បិ ៖ អត់ស្គាល់ទេ ។

ប៊ុនថន ៖ ឈ្មោះ យ៉ាន់អីដែរស្គាល់?

បិ ៖ មិនស្គាល់ទេ ពុតែឈ្មោះ មិនដឹងណា តាមប៉ុស្តិ៍ភ៉ាដូក្រោយ សមមិត្តយ៉ាន់ សមមិត្តអី ខ្ញុំមិនដែលឃើញអី ។

ប៊ុនថន ៖ គាត់យ៉ាននឹងនៅសមាជិកស្រុក?

បិ ៖ ពួកស្រុក ។

ប៊ុនថន ៖ ហើយឈ្មោះ ម៉េត ប្រធានសហករណ៍ភាសអី ពូដែលស្គាល់ទេ?

បិ ៖ ឈ្មោះ ម៉េត ស្គាល់ ម៉េតនៅកើត នៅព្រះនេត្រថ្មពួក ។

ប៊ុនថន ៖ បាទ! ខាងភាសន៍ ។ ពូនៅប្រធានក្រុមរហូត ពូមានដូរទៅខាងណាទៀត?

បិ ៖ ដូរៗចេញពីនោះមក ដល់ខាងក្រោយមកដូរចេញទៅខាងនៅពួកម៉ែៗបិទទំនប់នៅគ្រោះ ។

ប៊ុនថន ៖ ទំនប់អីវិញ?

បិ ៖ ទំនប់គ្រោះដែលដាច់ខូច ។

ប៊ុនថន ៖ ពូនៅខាងកងដដែល?

បិ ៖ នៅកាន់ខាងកងដដែល ប៉ុនមកកាន់ពួកម៉ែៗបិទទំនប់ គ្រាន់ដកពីកន្លែងនោះមកឲ្យមកកាន់កងខាងគេបិទលើកទំនប់ ។

ប៊ុនថន ៖ ហើយប៉ុន្មាននាក់ កងម៉ែៗ?

បិ ៖ កងនោះ ពួកប្រពន្ធខ្ញុំនេះឯងកងប៉ុន្មាននាក់ នៅវ័យកណ្តាល ។

ប៊ុនថន ៖ គេកាន់ផ្សេងទៀត?

បិ ៖ គេទៅផ្សេងទៀតទៅ ។

ប៊ុនថន ៖ បិទទំនប់នឹងបិទតែខែវស្សា?

បិ ៖ បិទថ្ងៃ បិទសម្រាប់ខែវស្សា បិទថាខែប្រាំងយើងពិសាខហើយ អាខែធ្លាក់ភក្លៀងតិចៗ អាដីហុយយើងនេះ គេបិទនោះគេមានកំណត់ម្នាក់ម៉ាម៉ែត្រគីប ។

ប៊ុនថន ៖ ម្នាក់ម៉ាម៉ែត្រគីប?

បិ ៖ ម្នាក់ម៉ាម៉ែត្រគីប អ្នកណារួចទៅសម្រាកទៅចេះ ម៉ាម៉ែត្រគីបដីគេដីកមានតើ ។

ប៊ុនថន ៖ ចុះបើអត់រួច?

បិ ៖ អត់រួចតែខំទៅ អ្នកណារួចមុនគេសម្រាកមុនទៅ ចែកគ្នាស្រេចហើយ ម្នាក់ម៉ាម៉ែត្រគីប គេដីកដីបានម៉ាម៉ែត្រគីបវែកចាក់លើទំនប់រួចស្រេចហើយ សម្រាក ។

ប៊ុនថន ៖ ចុះកងពូដែលធ្វើទាន់ ដែលមានធ្វើអត់ទាន់?

បិ ៖ ម៉ាម៉ែត្រគីបធ្វើទាន់តើ ម៉ាព្រឹកម៉ាម៉ែត្រគីប ល្ងាចម៉ាម៉ែត្រគីប ចេញច្រើនធ្វើទាន់ ។

ប៊ុនថន ៖ ចុះបើអ្នកធ្វើអត់ទាន់?

បិ ៖ អត់នេះទេ ទាន់ម៉ាម៉ែត្រគីប មិនយូរប៉ុន្មានទេ ។

ប៊ុនថន ៖ បើអ្នកធ្វើអត់ទាន់?

បិ ៖ មិនមានអ្នកធ្វើមិនទាន់ ធ្វើទាន់ ។

ប៊ុនថន ៖ ត្រូវធ្វើបន្ថែមឲ្យហើយ?

បិ ៖ ត្រូវធ្វើបន្ថែមឲ្យហើយ ធ្វើម៉េចឲ្យបានប៉ុននឹងម៉ាថ្ងៃឲ្យបាន២ម៉ែត្រគីប ព្រឹកម៉ាម៉ែត្រគីប ល្ងាចម៉ាម៉ែត្រគីប មិនត្រូវបន្ទុំទេ អាស្រ័យកូនតូចៗដែរ ។

ប៊ុនថន ៖ ពូនៅនឹងដល់ឆ្នាំប៉ុន្មានពូកងម៉ែៗ?

បិ ៖ កងម៉ែៗឆ្នាំអឺ!ចុងក្រោយ ឆ្នាំជិតបែក អឺ!៧៦ចុងឆ្នាំ៧៦ ហើយដល់ឆ្នាំ៧៦ចប់ទៅបាន គេឲ្យមកនៅច្រូតនៅវាលឆ្នាំ៧៧ ។ ច្រូតស្រូវយើងអស់ហើយពួកវៀតណាមមករំដោះៗ នៅអាខេត្តចូលអត់ទាន់រួចទេ ។

ប៊ុនថន ៖ ពូមក៧៧ ខាងច្រូត?

បិ ៖ បាទ! ៧៧ខាងច្រូត នៅខាងទំនប់នគរខាងលិចភូមិគំរូយើង ។ ដល់ពេលវថក្រោះបាញ់គ្នានោះទៅ ឯនេះវារៀបចំហើយ ខ្មែរក្រហមរៀបចំអីវ៉ាន់ដាក់ ។ ពេលសង្គ្រាមចូលដល់វា រើសគោរើស សម្រាប់គោណាលឿនៗគោណាធំៗសម្រាប់ដឹកជញ្ជូនរត់ ។ ដល់ហើយបាញ់ចេញពីម្កាក់ចេញពី....គោធ្ងន់ខែមាឃហើយ វាអស់ស្រូវស្រាលហើយ នៅតែស្រូវធ្ងន់វាចូលទឹក ដែលពួកវៀតណាមរំដោះយើងមកនេះ ពីភ្នំពេញរំដោះរួចហើយ ។ យើងនេះនៅក្រោយគេ ។ ដល់ហើយវៀតណាម ឮតែល្បឺថាវថក្រោះបាញ់មិនឆេះយើងខ្លាចហើយយើងត្រៀមកំទេចត្រៀមអីដាក់អីវ៉ាន់ ដល់មកជិតហើយល្ងាចប៉ុននេះ រត់ចោលឯង ទៅ...នាំគ្នារត់មកផ្ទះវិញ ។

ប៊ុនថន ៖ បាទ! ចឹងពូខាងខ្មែរក្រហមប្រធានសហករណ៍អីរត់ចេញអត់?

បិ ៖ រត់ចេញអត់ហើយ ។

ប៊ុនថន ៖ តែពួអត់រត់ទៅៗ?

បិ ៖ ទេ! អត់រត់ទេ នាំប្រពន្ធកូននៅផ្ទះ មកពួកវៀតណាមវាឡើងដល់សាលាកាលេះយើង ប្តោងដាក់មក គេចខ្លួនទៅគេផ្អើលរត់មក ទាល់ល្ងាចឡើងរត់ចូលផ្ទះៗមក ។ ភ្លើងឆេះផ្ទះ វាប្តោងចំផ្ទះឆេះអស់ ។ ដល់ពេលមកនឹងគ្រប់ក្រសួងមកសម្រាក ភ្លើងឆេះអស់…។

ប៊ុនថន ៖ ម៉េចបានពូអត់សម្រេចចិត្តទៅជាមួយ?

បិ ៖ មិនទៅទេ ព្រោះអីមាននែក!អ្នកប្រជាពលរដ្ឋចាស់ដែលគេធ្វើយោធា មកនៅផ្ទះនេះអ្នកភ្នំពេញមិនទៅស្រុកវិញនៅសព្វថ្ងៃ ចុះកាលនឹងប្រធានយោធាមកនៅនេះ ហៅខ្ញុំមកនៅគេបានឲ្យហូប មកហូបបាយ ខ្ញុំមិនចេះហូបស្រាទេ ។ គេមានស្រាហូប ហូបស្រារួចអត់ថាទេ ខ្ញុំមិនចេះទេ ។ ឯងមិនចេះមែន ចឹងហូបតែបាយទៅចុះ ។ ប្អូនឯងភូមិយើងស្គាត់ទេ ក្នុងបច្ចុប្បន្ននេះ ថាគេកំពុងដឹកនាំគ្រប់គ្រងកងចក្រយើង….។ យកជើងយកដៃទៅវាហើយបើថាគេចាញ់ពួក….កុំទៅ

នៅស្រុកនៅភូមិយើងទៅស្រណុកជាងស្រួលជាងកុំពិបាក រត់តាមគេ ។ ហើយខ្ញុំទៅណាទៅ ស្រុកភូមិដី នៅនេះតាំងពីអើយមក មិនទៅតាមគេទេ តាមគេកុំតាមគេៗចាញ់សង្គ្រាមរត់ចេញពីស្រុកពីភូមិគេដេញចេញពីស្រុកពីភូមិ ។ គេដេញម៉ង់ពួកនឹង ។ ហើយថាកូនឯងកុំរត់តាមណាតាមគេទៅណាទៅណៃ ។ ហើយខ្ញុំអត់ទៅទេ គេដើរមកប្រឹប ហើយខ្ញុំនៅផ្ទះម៉ែខ្ញុំ ឆេះផ្ទះអស់ទៅនៅផ្ទះម៉ែខ្ញុំ ។ ដឹកគ្រាន់សេរ បងប្អូនម៉ែឪ ម៉ែៗប្អូនៗ បងៗចូលក្នុងគេធ្វើគ្រាន់សេរណាៗ ប៉ុលពតទៅតាមៗយួនមកអារក ធាងត្នោតស្លាប់មាំហើយ ទៅតាមខ្ញុំមក អូ!មិនបានទៅទេ ទៅតែឯងទេ ។ អានេះគេរត់ទៅតែឯង ។

ប៊ុនថន ៖ អ្នកណាគេហៅទៅ?

បិ ៖ អ្នកភូមិអ្នកខ្មែរក្រហម គេផ្អើលបាញ់គ្នា ។ ហើយដល់មកៗទៅតាមខ្ញុំមក កុំនៅជាមួយយួនគ្នាអារកធាងត្នោតងាប់ ។ ដល់ពេលអឺ!វៀតណាមចូលមកដល់ ភ្លង់កាំភ្លើងខ្ញុំឡើងគ្រាន់ ខ្ញុំប្រជាជនៗទេ វាថាប៉ុលពតៗ ។ មានអីវាចេះតែដេញតាម ។ ដល់អាគងមកក្រោយ នេះវាចាប់ឯងប្រុសៗ ទាំងអស់គេដឹកទៅដាក់គុកនៅស្វាយ ថាឯងប៉ុលពតចាប់ប្រជាពលរដ្ឋទាំងអស់ឲ្យតែប្រុសៗ នៅតែស្រីៗ ។ ហើយអាពួកខ្មែរក្រហមក៏វាចេញដល់ក្រៅវាតបមកវិញ ហើយដល់ចាប់អាប្រុសៗទៅ ឲ្យពួកស្រីៗនិងតាចាស់មិនដែល

បានចាប់ ឲ្យរៀបចំជម្រៀសចេញម៉ាថ្ងៃ២ថ្ងៃទៅតាមគេ គេឲ្យដើរៗទៅតាមស្វាយ គេឲ្យនៅម្ដាក់ យើងនោះ ទៅនៅទូកមាសនោះ ចេញទាំងអស់យប់ឡើងឃើញភ្លឺចង្កៀងអុចភូមិ អុចផ្ទះ ចោល ។

ប៊ុនថន : ពីណាអុ៊ច?

បិ : មិនដឹងអ្នកណា មិនដឹងជាតាម ។

ប៊ុនថន : ខ្មែរក្រហម?

បិ : មិនដឹងជាខ្មែរក្រហម ដល់វៀតណាមនៅនេះវៀតណាមគេចេញ វៀតណាមទៅក្រោយដល់នេះទៅចេញផុត វាឃើញភ្លើង....។ ហើយដល់កន្លែងនោះវា អឺ!ទៅដល់៥ថ្ងៃ ខាងខ្មោចចេញចាស់ៗមិនដល់ម៉ាឆ្នាំ ចាប់ច្រើនណាស់ទាំងអស់ឲ្យតែឃើញប្រុសៗ ។ ដល់ថ្ងៃចូលឆ្នាំខ្មែរនឹងបានវាលែងមកវិញទាំងអស់ ហើយដល់ចូលឆ្នាំរួចនេះបានគេឲ្យមក ថាអឺ!ថ្មពួកគេរំដោះបានហើយ គេឲ្យមកភូមិវិញ ។

ប៊ុនថន : ចុះពូយោធាស្រុកថាមកហៅពូទៅជួបនឹងឈ្មោះអីគេវិញ?

បិ : ពីណា?

ប៊ុនថន : យោធាស្រុកថាប្រាប់ពូកុំឲ្យរត់នឹង?

បិ : យោធាស្រុក ។

ប៊ុនថន : ខាងយើងនេះ?

បិ : នែក! គាត់យោធាដែលមកពីខាងសង្គ្រាមរំដោះមុនណា ។

ប៊ុនថន : គាត់ឈ្មោះអី?

បិ : ហឿនៗ ។

ប៊ុនថន : គាត់នៅរស់តើ?

បិ : មិនដឹងរស់ឬងាប់ទេ រត់តាមគ្នានៅណា ។

ប៊ុនថន : គាត់ថា គាត់រាប់អានជិតស្និតជាមួយពូ បានហៅពូមកប្រាប់?

បិ : ដល់នេះទៅ ឯងនៅ២នាក់ប្ដីប្រពន្ធគាត់ស្រណោះ ក៏ហៅទៅអង្គុយនិយាយលេង ក៏ប្រាប់នេះទៅស្គាល់រាប់អានគាត់ដូចឪធម៌ ។

ប៊ុនថន : គាត់តួនាទីគាត់យោធាស្រុក?

បិ : យោធាស្រុក ។

ប៊ុនថន : ហើយពូថាមិញ គាត់មានស្រាមានអីហូបដែរ?

បិ ៖ មុនដំបូងគាត់មានស្រា គេខាងនោះគេមាន ។

ប៊ុនថន ៖ ខាងយោធានឹង?

បិ ៖ ខាងយោធា តាំងពីបារីកញ្ចប់ បារីសេក បារីតោក៏មានទាំងអស់ដែរ ដែលគេបានពីផ្សារធំៗនោះមក ពីស្វាយតាមអីនោះ ។ ត្រង់នេះជម្លៀសចេញមកទាំងអស់គ្នាគ្មានអីបាននៅទាំងអស់គ្រប់ ភ្នំពេញអីកន្លែងណាចេញពីទីក្រុងដូចខេត្ត ដូចស្វាយដូចបាត់ដំបងអីមក ប្រជាជនយើងជាម្ចាស់ផ្ទះ ជាម្ចាស់មូលដ្ឋានគេឲ្យចេញទាំងអស់ គ្មានទុកយើងទេ ចេញបន្ត បន្ទាប់តាមផ្លូវអ្នកណាទៅមិនរួចគេថែមទៅ ។

ប៊ុនថន ៖ ពេលហ្នឹងពូនឹងមានមនុស្សច្រើនទេ?

បិ ៖ អត់ទេ តែក្នុងគ្រួសារគាត់នឹង បើគ្រួសារគាត់គេមកនៅផ្ទះ២-៣នាក់ ហើយគាត់នេះកាល គាត់អាយុប៉ុននោះមិនទាន់ដល់៥០ផងនៅ៤០ជាង ខ្ញុំកាលនោះទើប២៥ ។ អាយុខ្ញុំកាលឆ្នាំ៧៥ ពេលខ្ញុំបានគ្រួសារនឹងអាយុ២៥ ។

ប៊ុនថន ៖ ចុះបែកវៀតណាមចូលមកនឹងគាត់រត់ទៅណា?

បិ ៖ បែកវៀតណាម ទៅតាមគ្នាគេអស់ហើយ រត់តាមខ្មែរក្រហមទៅនៅតាមព្រំដែន នៅព្រៃមាន់ព្រៃអី ភ្នំឆ័ត្ររត់គរគ្នានោះឯង ។

ប៊ុនថន ៖ ក្រោយមកពូមានបានព្ងដំណឹងអីទេ?

បិ ៖ អត់ ស្ងាត់ជ្រាប មិនឃើញ ។

ប៊ុនថន ៖ ចុះពូក្រោយពីដោះលែងពូមកពីគុកហើយ ពូមកភូមិនេះវិញ ឬយ៉ាងម៉េច?

បិ ៖ អង្គការស្វាយ(ស្វាយស៊ីសាផុន) យើង យកទៅដាក់នោះ ហើយដោះលែងមក ឲ្យបងប្អូនយាយតាស្រីនៅម្នាក់ៗ យើងចេញពីស្វាយមកនៅជួបជុំគ្រួសារយើង ដល់ពេលចូលឆ្នាំហើយបានគេឲ្យមកនៅភូមិនេះវិញ មកថ្មពួកវិញ ។

ប៊ុនថន ៖ មកថ្មពួក?

បិ ៖ បាទ!

ប៊ុនថន ៖ មកដល់នឹង?

បិ ៖ មកដល់នឹងស្ងាត់ជ្រាប អត់មានអ្នកណាអី ។

ប៊ុនថន ៖ បាទ! ចាត់កម្លាំងតាម មាន?

បិ ៖ កម្លាំងណា បើអត់មានឃើញផង កម្លាំងដកទៅនៅណា អត់ឃើញផង ។ ដល់យូរៗបានមានខ្មែរក្រហម មកចូលមក បានវៀតណាមចូលមកដាក់ការពារឲ្យ ។ ពួកខ្មែរក្រហមនៅ

ព្រៃមកបាញ់ថ្នោង ល្ងាចបាញ់ថ្នោងទៅកើតអស់ហើយ ។ យើងតែម៉ោង៥ដាំបាយហូបរួច យើងដាំនៅត្រង់សេរអត់ហើយ ។ តែនេះមកប៉ារ៉ាមកគេថ្នោងមកគេថ្នោងដាក់ វៀតណាមនៅខ្មែរត្រៀមក្រវ៉ាត់ពេញភូមិនឹង ។

ប៊ុនថន : ចុះដែលចូលមកដល់ភូមិទេ ប៉ារ៉ា ខ្មែរក្រហម?

បិ : អត់ចូលដល់រួចទេ បើកាលដែលខ្មែរក្រហមដកទៅនៅស្វាយចេក ឃើញប៉ារ៉ាចូលដល់ភូមិ ដល់ពេលប៉ារ៉ាចូលមកម្ដងៗចេះទៅ រត់ទៅវិញទៅ ហើយដល់ពេលនេះរើសឃុំ រើសមេភូមិអី ហើយដល់មេឃុំរើសនឹងថ្មពួកនេះទេ ។ ដល់វៀតណាមមកស៊ើបការណ៍មកនៅភូមិ៤-១០នាក់ទៅប៉ារ៉ាកំពុងបាញ់ងាប់២នាក់ត្រង់នេះ....កងទ័ពគេមកនេះ... ។

ប៊ុនថន : កងទ័ពវៀតណាម?

បិ : ដាក់ជុំវិញស្រុកថ្មពួក ។

ប៊ុនថន : បាទ! ចូលលែងបាន?

បិ : កាលមកទំនាក់ទំនង១០នាក់ ចូលមកដើម្បីទំនាក់ទំនងជាមួយពួកឃុំដែលរើសបានហើយ ហើយមេឃុំនោះឈ្មោះតាឈឿនៗ ។ ហើយដល់គេមក៤-១០នាក់ទៅ ឃើញកម្លាំងគេតិចពួកប៉ារ៉ាគេបាញ់គ្នា២នាក់ទៅ យកខ្មោចទៅ ។ ខាងនេះគេបញ្ជូនទ័ពមកច្រើន ។

ប៊ុនថន : បាញ់វៀតណាម?

បិ : បាញ់វៀតណាមងាប់អស់២នាក់ វៀតណាមមក៥នាក់ ហើយដល់នេះបញ្ជូនទ័ពមកពេញទឹកពេញដីតែម្ដង ។

ប៊ុនថន : ចុះពូមានចូលធ្វើការអីវិញទេ គេជ្រើសរើស?

បិ : នែក! ខ្ញុំមេក្រុមគេ មេក្រុមកាលចូលមកហើយ មេក្រុមសាមគ្គីគេរំដោះគាត់ម្ដងទៀត ដល់ ១០គ្រួសារម៉ាក្រុម នោះទៅរៀនតាំងស្រុកស្វាយចេកទៅរៀននយោបាយជាមួយលោកមេឃុំធួនប្រធាន ប្រជុំជាមួយគ្នារហូតលុះសព្វថ្ងៃ ។ សព្វថ្ងៃដែលយើងឈរនៅបក្សប្រជាជន ដល់ពេលបោះឆ្នោតបោះអីមេឃុំ មេឃុំពួកម៉ាក់គ្នា ។

ប៊ុនថន : ឥឡូវពូនៅទៀតទេ នៅធ្វើ?

បិ : ការងារនៅធ្វើសព្វថ្ងៃ មេភូមិអីដាក់តាមការងារ ហើយសុទ្ធតែមេៗ ។

ប៊ុនថន : ហើយកូនចៅប៉ុន្មាននាក់ហើយ?

បិ : ខ្ញុំ៦ ស្រី២ ប្រុស៤ ធ្វើប៉ូលីស២ ប្រុសលិ្មត២ ស្រី២ក្រោយៗនេះមួយ កូនចិននេះមួយ ។

ប៊ុនថន ៖	បាទ! ៧នាក់?

បិ ៖	៧នាក់ ម៉ែឪវាមានផ្ញើពេទ្យ យកវាមកនៅម្នាក់.........។

ប៊ុនថន ៖	បាទ! ហើយខ្ញុំដូចអស់អីសួរពូហើយ ពូមានអីចង់បន្ថែមទៀតទេ?

បិ ៖	ទេ! អត់អីទេ គ្រាន់ថាពីនោះមកការងាររដ្ឋាភិបាលជនួយរដ្ឋកម្ពុជាគឺបានរស់ពូថ្ងៃ។

ប៊ុនថន ៖	បាទៗ អរគុណច្រើនលោកពូណា។

«ចប់»